# សិលាចារឹករកឃើញថ្មីនៅជើងភ្នំត្រប់

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ នេះ អ្នកស្រុកបានរកឃើញសិលាចារឹកថ្មីមួយនៅខាងលិចជើងភ្នំត្រប់ ស្ថិតនៅក្នុងឃុំត្រប់ ស្រុកបាធាយ ខេត្តកំពង់ចាម ដែលជាទីតាំងពុទ្ធសាសនាមហាយានដ៏ល្បីល្បាញមួយតាំងពីសម័យអង្គររហូតមក។ ប្រាសាទភ្នំត្រប់ជាប្រាសាទសាងឡើងស.វ.ទី១០ ផ្ដែរស្ថិតក្នុងរចនាបថប្រែរូប នៅលើជញ្ជាំងមានចម្លាក់ដូចប្រាសាទក្រវាន់ផងដែរ[1]។ ចម្លាក់ទាំងនោះ នៅក្ដីឬប៉ មខាងជើង ជាចម្លាក់វជ្របាណីនៅក្ដីឬប៉មកណ្ដាល ជាចម្លាក់ព្រះអវលោកិតេសូរព្រះហស្ដបួននិងពោធិសត្វប្រាជ្ញាបារមីតា និងនៅក្ដីឬប៉មខាងត្បូងក៏ជាព្រះអវលោកិតេសូរដែរ ប៉ុន្តែមានព្រះហស្ដប្រាំបីនិងមានប្រាជ្ញាបារមីតានៅអមសង្ខាងដូចក្ដីឬប៉មខាងជើងដែរ[2]។ នៅតំបន់នោះក៏មានទីតាំងដទៃទៀតដូចជា ទួលជីទេព ឬទួលកំណាប់ អ្នកស្រាវជ្រាវបានរកឃើញបដិមាបីអង្គ ស្ថិតក្នុងរចនាបថបន្ទាយស្រី ដែលកំណត់បានថាជាព្រះក្នុងពុទ្ធសាសនានិយាកវជ្រយាន ឬពេជ្រយាន។

តាមរយៈភិក្ខុបណ្ឌារក្ខត្ដេពោ ទៀង ប៉េងអៀង ជាប្រិយមិត្តមួយអង្គរបស់ AMS អរិយធម៌ខ្មែរ បានផ្ដល់ដំណឹងអំពីសិលាចារឹកនេះមកក្រុមងាររបស់យើងនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។ ក្រោយពីបានទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមការងារបានចុះទៅប្រមូលទិន្នន័យអំពីសិលាចារឹកនេះ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។ សិលាចារឹកនេះរកឃើញ នៅដីស្រែតយាយដិប ក្នុងភូមិទំព្រង ក្បែរទីទួលមួយ អំឡុងពេលបកយកដីស្រែដើម្បីយកមកចាក់បំពេញបរិវេណផ្ទះ។ នៅថ្ងៃរកឃើញដដែលនេះ អ្នកស្រុកក៏មូលមតិគ្នាប្រគល់សិលាចារឹកមួយផ្ទាំងនេះដល់អាជ្ញាឃុំត្រប់ ដើម្បីរក្សាទុកនៅក្នុងបរិវេណសាលាឃុំត្រប់។ ថ្មីៗនេះ អាជ្ញាធរឃុំត្រប់ ក៏បានចាក់សិលាចារឹកនេះភ្ជាប់នឹងស៊ីម៉ង់ដាក់នៅក្នុងសាលាឃុំ។

---

[1] អានបន្ថែម៖ http://www.yosothor.org/publications/khmer-renaissance/chapter-four/phnom-trob.html

[2] អានលម្អិត៖ សួន សុក័ត្រា ២០១៨។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

សិលាចារឹកនេះមានកម្ពស់៨៨ស.ម. (ពុំគិតជម្រៅកប់ក្នុងស៊ីម៉ង់) បន្ទារអប្បបរិមា ៤៧ស.ម. អតិបរមា៥២ស.ម. និងមានកម្រាស់៧ស.ម.។ ផ្ទៃអត្ថបទមានកម្ពស់៤៨,៥ ស.ម. បន្ទារ៤៦ស.ម. កម្ពស់អក្សរជាមធ្យម១ស.ម. និងមានគម្លាតរវាងបន្ទាត់នីមួយៗ ១ស.ម.។ តួអក្សរសិលាចារឹកនេះ ចារឡើងដោយផ្ចិតផ្ចង់ មានសោភ័ណ ប្រកបដោយទឹកដៃសិល្បៈខ្ពស់។ ជម្រៅចារអក្សរ ជ្រៅដោយអន្ទើ ភាគច្រើនមានជម្រៅមធ្យម និងនៅចុងអត្ថបទមានជម្រៅរាក់។ សិលាចារឹកនេះ ចារលើថ្មភក់ រចនារាងជាសន្ទឹកសីមា ធំលើ រាវក្រោម ផ្នែកខាងក្រោមបំផុតរាងធំជាផ្នែកបញ្ចុះក្នុងជើងទម្រ។ ទីតាំងរកឃើញសិលាចារឹកនេះ ហាក់ពុំសមជាទីតាំងដើមនោះទេ ដែលទំនងជាសិលាចារឹកនេះ ត្រូវគេចល័តចេញពីទីតាំងដើមនៅតំបន់ភ្នំត្រប់នេះ នាសម័យកាលណាមួយ។ ដោយយល់រៀបនេះ ដ្បិតយើងពុំឃើញមានវត្ថុសិល្បៈដទៃទៀត ដែលអាចមានជាជើងទម្រសិលាចារឹក បំណែកបដិមានានា ថ្មប្រាសាទ ជាដើម។ នៅទីតាំងនោះ មានតែថ្មគោលមួយ ដែលសាងពីថ្មភក់ខ្ចី មានគ្រាប់ខ្សាច់និងគ្រួសធំៗ មិនសម្អាតផ្ទៃថ្មឱ្យស្មើល្អ និងបំណែកកុលាលភាជន៍មួយចំនួនប៉ុណ្ណោះ។ សិលាចារឹកដ៏វិចិត្របែបនេះ សមណាស់តែនៅទីតាំងដ៏ល្អមួយ។

អត្ថបទនេះចារឡើងជាភាសាសំស្ក្រឹត នៅក្នុងអំឡុងស.វ.ទី១១ ស្ថិតនៅក្នុងរាជ្យព្រះបាទសូរ្យវម៌្មទេវទី១ (សូរ្យវរ្ម័នទី១ ១០០២-១០៥០ គ.ស.)។ អត្ថបទចាប់ផ្តើមឡើងដោយនមស្ការចំពោះព្រះពុទ្ធដ៏ជាព្រះឈ្នះមារ ព្រះអវលោកិតេស្វរ និងព្រះវជ្របាណី។ សេចក្តីបន្ទាត់ ជាសេចក្តីលើកសរសើរពីព្រះបាទសូរ្យវម៌្មទេវទី១។ ព្រះអង្គបានកសាងប្រាសាទបី បន្ទាយប្រាការ វលភិ[៣] ស្រះទឹក ច្បារដំណាំ និងអាស្រមផង។ ព្រះអង្គមានមន្ត្រីម្នាក់ឈ្មោះថា ស្រីជយេន្ទ្រាយុធ ដ៏មានភក្តីភាពចំពោះទ្រង់បានថ្វាយមធ្យោបាយចំពោះទេព គឺតង្វាយអម្រស់អម្រដល់ប្រាសាទមានដូចជា អ្នកបម្រើប្រុសស្រី(ក្នុងសិលាចារឹកប្រើពាក្យ ទាសីទាស) ទីក្រុង(បុរ) ភូមិ(គ្រាម) ដីស្រែ(ក្សេត្រ)។ សេចក្តីចុងបញ្ចប់ មិន

[៣] លោក ឡេង ស៊ីវ៉ង់ បេក្ខជនបណ្ឌិតផ្នែកប្រវត្តិសិល្បៈបានពន្យល់តាមការសន្ទនាថា «ប្រភេទប្រាសាទទោលមានបន្ទប់មួយ ដោយស្ថាបត្យកម្មប្រភេទនេះខ្មែរនិយមហៅថាបណ្ណាល័យ ឬ ហោត្រ័យ។ ហើយទម្រង់ស្ថាបត្យកម្មនេះក៏មានលក្ខណៈដូចគ្នានឹងទម្រង់ប្រាសាទឥណ្ឌាមួយប្រភេទគឺ ប្រាសាទប្រភេទវលភិ (ពាក្យស្ថាបត្យកម្មឥណ្ឌាខាងជើង) ឬប្រាសាទទម្រង់សាល (ពាក្យស្ថាបត្យកម្មឥណ្ឌាខាងត្បូង)»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ខុសប្លែកពីអ្វីដែលធ្លាប់ឃើញនៅក្នុងសិលាចារឹកជាច្រើននោះទេ គឺជាពាក្យផ្តាសាដល់នរណាដែលបានបំផ្លាញបុណ្យដែលបានកសាងទាំងនោះ ឱ្យនរូជននោះធ្លាក់ទៅរងទុក្ខទោសនៅឯអវិចីស្ថាន។ ចំណែកនរជនឯណាដែលបានថែរក្សាសមិទ្ធិទាំងនោះ ក៏នឹងទទួលបានភាគបុណ្យផងដែរ។

គួររំលឹកផងដែរថា បទនមស្ការចំពោះប្រជុំបីនៃព្រះក្នុងពុទ្ធសាសនានិកាយវជ្រយានមានព្រះពុទ្ធ ព្រះអវលោកិតេស្វរ និងព្រះវជ្របាណី ក្នុងសិលាចារឹកនេះ គឺត្រូវគ្នានឹងរូបបដិមាដែលបានរកឃើញនៅទួលជីទេព ឬទួលកំណាប់ ព្រមទាំងប្រាសាទនៅលើភ្នំត្រប់ដែលមានចម្លាក់ព្រះអវលោកិតេស្វរ ប្រាជ្ញាបារមីតា និងវជ្របាណី។ តាមរយៈសិលាចារឹកដែលរកឃើញកន្លងមក សិលាចារឹកនៅប្រាសាទបាតជុំដែលជាប្រាសាទពុទ្ធសាសនាវជ្រយាន ក៏មានបទនមស្ការឧទ្ទិសដល់ព្រះពុទ្ធ ព្រះអវលោកិតេស្វរ និងព្រះវជ្របាណីផងដែរ[៤]។ នៅទីតាំងទួលព្រះប ក៏មានបដិមាព្រះពុទ្ធប្រក់នាគមួយព្រះអង្គនាសម័យអង្គរផងដែរ ប៉ុន្តែគួរឱ្យស្តាយ បដិមានេះបានខូចខាតអស់ច្រើនទៅហើយ។ នៅទីតាំងដដែលនេះក៏មានសិលាចារឹកភាសាខ្មែរស.វ.ទី១១មួយផ្ទាំង ដែលសឹករេចរឹលស្ទើរតែទាំងស្រុងផងដែរ ដែលជាប្រការនាំឱ្យបាត់បង់កស្តុតាងអំពីទីតាំងនេះ។ យ៉ាងណាក្តី កស្តុតាងជាច្រើនមកនេះ បង្ហាញថាតំបន់ភ្នំត្រប់ ជាទីតាំងពុទ្ធសាសនាវជ្រយានដ៏ធំមួយចាប់ពីស.វ.ទី១០មក។ ទោះជាត្រឡប់មកកាន់ពុទ្ធសាសនាថេរវាទវិញ អ្នកស្រុកនិងទីតាំងបុរាណដ្ឋានទាំងឡាយដែលខ្លះខូចខាតបាត់បង់រូបរាង ខ្លះទ្រុឌទ្រោមក្តី ខ្លះជាប្រាសាទខាងសាសនាព្រាហ្មណ៍ក្តី ក៏អ្នកស្រុកនៅតែគោរពបូជា បន្តកសាងពុំដាច់៕

[៤] សួន សុភ័ក្រ្តា ២០២០។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ង៉ោ ដោត មេឃុំត្រប់ និងសមាជិកឃុំទាំងអស់ ដែលបានទទួលស្វាគមន៍ដំណើរស្រាវជ្រាវរបស់ខ្ញុំ។ ក្នុងនោះដែរក៏សូមអរព្រះគុណ ចំពោះព្រះភិក្ខុបណ្ណារក្ខត្ថេរោ ទៀង ប៉េងអៀង ដែលបានផ្តល់ព័ត៌មានអំពីសិលាចារឹកនេះមកកាន់ក្រុមការងារ AMS អរិយធម៌ខ្មែរ មួយអន្លើដោយព្រះសង្ឃនិងលោកតាអាចារ្យវត្តទាំងឡាយ ដែលបានផ្តល់ព័ត៌មានអំពីប្រវត្តិនៃការរកឃើញ និងជូនដំណើរដល់ទីតាំងរកឃើញសិលាចារឹកនេះផងដែរ។ ចុងក្រោយ សូមថ្លែងអំណរគុណចំពោះអ្នកគ្រូ គី សៀកគីម ជាគ្រូបង្រៀននៅវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សណ្តែក ដែលបានជួយសម្របសម្រួលដល់ដំណើរស្រាវជ្រាវនេះ។

## បញ្ជីឯកសារ

សួន សុភ័ក្ត្រា

២០១៨. ភស្តុតាងពុទ្ធសាសនាវជ្រយាននៅភាគអាគ្នេយ៍ប្រទេសកម្ពុជា. សារណាបរិញ្ញាបត្របុរាណវិទ្យា. មហាវិទ្យាល័យបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

២០២០. ប្រតិមាពុទ្ធសាសនានៅភ្នំត្រប់. កម្ពុជសុរិយា. លេខ៣។

## បញ្ជីរូបភាព



ទីតាំងរកឃើញសិលាចារឹក (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



ព្រះសង្ឃនិងតាអាចារ្យវត្តប្រើសមាសនាំផ្លូវបង្ហាញទីតាំងរកឃើញសិលាចារឹក (រូបថតៈ ហ៊ុន ឈុនតេង)



ថ្មគោល រកឃើញជាមួយសិលាចារឹក (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



រូបថតសិលាចារឹករកឃើញនៅជើងភ្នំត្រប់ (រូបថតៈ ហ៊ុន ឈុនតេង)



ទីតាំងរក្សាទុកសិលាចារឹករកឃើញនៅជើងភ្នំត្រប់ (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង